ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. ០៩៨ MOC / SM 2008

# ប្រកាស
## ស្តីពី
## ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងប្រកាសអន្តរក្រសួងលេខ ៦៧៩ សហវ ប្រក . ចមព ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០៧ ស្តីពីកម្រៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម
- យោងតាមការចាំបាច់ ក្នុងទិសដៅកែទំរង់វិស័យចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្ម



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៨ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨

# សំរេច

**ប្រការ ១** : រាល់ពាណិជ្ជករនិងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលមានគ្រឹះស្ថានរបស់ខ្លួន សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬ ទីភ្នាក់ងាររបស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ ២** : ដើម្បីធានាអះអាង និង ទទួលខុសត្រូវលើរាល់សំណុំលិខិតដែលខ្លួនបានបំពេញ ឬ ដែលខ្លួនត្រូវបំពេញ និង ផ្តល់មកតំកល់នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មក្រសួងពាណិជ្ជកម្ម អភិបាលម្នាក់ឬម្ចាស់ហ៊ុនម្នាក់ ត្រូវមក ចុះហត្ថលេខាដោយផ្ទាល់ដៃ នៅចំពោះមុខមន្ត្រីនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ៣** : នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មានកាតព្វកិច្ចផ្តល់គំរូលក្ខន្តិកៈក្រុមហ៊ុនឱ្យអ្នកចុះបញ្ជី ។ ក្នុងករណីអ្នកចុះ បញ្ជីពឹងពាក់មេធាវី ឬក្រុមហ៊ុនច្បាប់ណាមួយជួយបំពេញលក្ខន្តិកៈឱ្យខ្លួន សោហ៊ុយសេវានេះគឺស្ថិតនៅក្រៅ រង្វង់អំណាចរដ្ឋបាលរបស់ក្រសួងពាណិជ្ជកម្ម ។ ក្រសួងពាណិជ្ជកម្មមិនទទួលខុសត្រូវលើសេវានោះទេ ។

**ប្រការ ៤** : នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម មានកាតព្វកិច្ចផ្តល់ជូននូវវិញ្ញាបនប័ត្រចុះបញ្ជី ( តាម គំរូថ្មី ) ដែលមានចែងអត្តលេខសំគាល់ចុះក្នុងបញ្ជីពាណិជ្ជកម្ម និងមានសុពលភាពរយៈពេល ៣ឆ្នាំ គិតចាប់ ពីកាលបរិច្ឆេទដែលបានទទួលចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ៥** : ក្នុងរយៈពេល ៣០ថ្ងៃ មុនថ្ងៃផុតកំណត់សុពលភាពនៃវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម រាល់សហគ្រាស-ក្រុមហ៊ុនពាណិជ្ជកម្ម ត្រូវមកស្នើសុំប្តូរយកវិញ្ញាបនប័ត្រថ្មី ដើម្បីបន្តសុពលភាពនៃវិញ្ញាបនប័ត្រចុះបញ្ជី ពាណិជ្ជកម្មនេះចំនួន ៣ ឆ្នាំ ជាបន្តបន្ទាប់ ។

**ប្រការ ៦** : ចំពោះសហគ្រាស-ក្រុមហ៊ុនពាណិជ្ជកម្មណា ដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរួចហើយ មុនការចេញ សេចក្តីប្រកាសនេះ ហើយដែលបានទទួលវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ( គំរូចាស់ ) ហួសរយៈពេល៣ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចុងក្រោយ នៃការចេញវិញ្ញាបនប័ត្រចាស់ មកទល់ថ្ងៃចេញសេចក្តីប្រកាសនេះ ត្រូវ អញ្ជើញមកធ្វើការប្តូរយកវិញ្ញាបនប័ត្រតាមគំរូថ្មីវិញ មិនអោយលើសរយៈពេល ៦ ខែ ក្រោយថ្ងៃចេញ សេចក្តីប្រកាសនេះ ។

**ប្រការ ៧** : ការប្តូរយកវិញ្ញាបនប័ត្រតាមគំរូថ្មីបន្តសុពលភាពនៃការចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានផ្តល់ជូនដោយនាយក ដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ដោយឥតគិតថ្លៃ ។

**ប្រការ ៨** : សហគ្រាស ឬ ក្រុមហ៊ុនពាណិជ្ជកម្មណាមួយ ខកខានពុំបានមកស្នើសុំបន្តសុពលភាពនៃវិញ្ញាបនប័ត្រចុះបញ្ជី ឬ ខកខានពុំបានមកធ្វើការប្តូរយកវិញ្ញាបនប័ត្រថ្មី តាមរយៈពេលកំណត់ ដូចចែងក្នុងប្រការ៥ និង ប្រការ៦ ខាងលើ សហគ្រាស ឬ ក្រុមហ៊ុនពាណិជ្ជកម្មនោះ នឹងត្រូវចាត់ទុកថាជាសហគ្រាស ឬ ក្រុមហ៊ុនមិនស្រប ច្បាប់ ហើយរាល់ឯកសារបញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ដែលក្រសួងពាណិជ្ជកម្មបានចេញជូន



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៥៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

នឹងត្រូវចាត់ទុកជានិរាករណ៍ ។

ក្នុងករណីនេះដែរ ដើម្បីទទួលបានមកវិញនូវវិញ្ញាបនប័ត្រចុះបញ្ជីថ្មីបន្តសុពលភាព សហគ្រាស ឬក្រុមហ៊ុនពាណិជ្ជកម្មនោះ ត្រូវស្នើសុំចុះបញ្ជីពាណិជ្ជកម្មសាជាថ្មីឡើងវិញ ដោយបង់កម្រៃរដ្ឋបាលចុះបញ្ជី ទៅតាមការកំណត់របស់រដ្ឋ ។

**ប្រការ ៩** : រាល់ពាណិជ្ជករឬអ្នកដឹកនាំក្រុមហ៊ុនទាំងឡាយណា ដែលប្រើប្រាស់ឯកសារក្លែងក្លាយដោយចេតនា នៅក្នុងទំនាក់ទំនងពាណិជ្ជកម្ម នឹងត្រូវផ្តន្ទាទោសស្របទៅតាមមាត្រា ៤៣ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ១០** : នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ត្រូវមានវិធានការសមស្រប ដើម្បីសហការជាមួយអភិបាល ឬ ម្ចាស់ហ៊ុន ដែលមកសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ដើម្បីជួយណែនាំ និង បង្កលក្ខណៈងាយស្រួលដល់ការចុះបញ្ជីពាណិជ្ជកម្ម ឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា ។

**ប្រការ ១១**: អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នាយកដ្ឋាននីតិកម្ម មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងទាំងអស់ ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់តាមខ្លឹមសារនៃសេចក្តីប្រកាសនេះ ។

**ប្រការ ១២**: ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តនីចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

<u>ចម្លងជូន</u> :

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី " ជូនជ្រាបជារបាយការណ៍
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្ត-ក្រុង ដើម្បីជួយផ្សព្វផ្សាយ
- ឯកសារ - កាលប្បវត្តិ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ.ថ្ងៃទី០៧..ខែមេសាឆ្នាំ២០០៨

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ម៉ម_សម្បត្តិ

Prakas on Business Registration/REG/HSR/KSH/PHMN/NC

ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៤៨ / ៩៩១-៧០៨
អ៊ីមែល : moccabdir@yahoo.com